ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ : ៣១៧២/២០ សវណ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់សន្លឹកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរគំរូថ្មីដែលមាន សញ្ញាសុវត្ថិភាពពិសេស (Hologram)

**ក្រសួងមហាផ្ទៃ** សូមជម្រាបជូនដល់សាធារណជន និងស្ថាប័នពាក់ព័ន្ធ មេត្តាជ្រាបថា៖ ក្នុងគោលបំណងធ្វើឱ្យសន្លឹកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ កាន់តែមានលក្ខណៈសុវត្ថិភាពខ្ពស់ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចចេញសន្លឹកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ គំរូថ្មីដែលមានសញ្ញាសុវត្ថិភាពពិសេស (Hologram) សម្រាប់ផ្តល់ជូនប្រជាពលរដ្ឋ ដើម្បីប្រើប្រាស់ ដូចមានគំរូជូនភ្ជាប់។

ចំពោះសន្លឹកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលកំពុងប្រើប្រាស់បច្ចុប្បន្ន នៅមានតម្លៃរហូតដល់អស់សុពលភាព។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងស្ថាប័នពាក់ព័ន្ធទាំងអស់ ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តតាមសមត្ថកិច្ច ។

ថ្ងៃពុធ ១១កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០២០

ទីស្តីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail: moi@interior.gov.kh web: www.interior.gov.kh




អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ គំរូចាស់




អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ គំរូថ្មី